# កិច្ចព្រមព្រៀង
# ស្តីពីទំនិញឆ្លងកាត់ទោង
# រដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ហៅកាត់ថា ភាគីចុះហត្ថលេខា ។

ក្នុងគោលបំណងពង្រឹងនិងពង្រីកថែមទៀតនូវទំនាក់ទំនងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម សំដៅរួមប្រាស្រ័យអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្នុងប្រទេសនិមួយៗ លើមូលដ្ឋានស្មើភាព មានផលប្រយោជន៍ទៅវិញទៅមក ។

បានព្រមព្រៀងគ្នាដូចតទៅ :

## ប្រការ ១

ភាគីចុះហត្ថលេខាទាំងពីរអនុញ្ញាតអោយនាំចេញទំនិញឆ្ពោះទៅកាន់ប្រទេសទី៣ ឬ នាំចូលទំនិញពីប្រទេស ទី ៣ ឬ ទំនិញដឹកជញ្ជូនពីតំបន់មួយទៅតំបន់មួយផ្សេងទៀត របស់ប្រទេសខ្លួនបានឆ្លងកាត់លើទឹកដីនៃភាគីម្ខាងទៀត ។

## ប្រការ២

ទំនិញឆ្លងកាត់ត្រូវបានអនុញ្ញាតអោយចេញ ឬ ចូលតាមច្រកព្រំដែនដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១. | ក្អមសំណ | កោះរកា | វិញ សឿង | ធឿង ភឿក |
| | | ទន្លេមេគង្គ | ទន្លេ សុង ទៀន | គីវ ឡុង |
| | ខេត្តកណ្តាល | ព្រៃវែង | ខេត្តអានយ៉ាង | ដុង ថាប |

| | | |
|---|---|---|
| ២. | បាវិត ( ខេត្តស្វាយរៀង )<br>ផ្លូវជាតិលេខ ១ | ម៉ុក បាយ ( ខេត្តតៃនិញ )<br>ផ្លូវជាតិលេខ ២២ A |
| ៣. | ត្រពាំងផ្លុង( ខេត្តកំពង់ចាម )<br>ផ្លូវជាតិលេខ ៧ | ស្មា ច់( ខេត្តតៃនិញ )<br>ផ្លូវជាតិលេខ ២២B |
| ៤. | អូររាំង ( ខេត្តមណ្ឌលគីរី )<br>ផ្លូវជាតិលេខ ១៤ | ប៊ូប្រាំង ( ខេត្តដាឡាក់ )<br>ផ្លូវជាតិលេខ ១៤ |
| ៥. | អណ្តូងពេជ្រ ( ខេត្តរតនគីរី )<br>ផ្លូវជាតិលេខ ១៩ | ឡេ ថាញ់ ( ខេត្តយ៉ាឡៃ )<br>ផ្លូវជាតិលេខ ១៩ |
| ៦. | ស្នួល ( ខេត្តក្រចេះ )<br>ផ្លូវជាតិលេខ ១៣ | បណោ ( ខេត្តបិញ ភឿក )<br>ផ្លូវជាតិលេខ ១៣ |
| ៧. | ភ្នំដិន ( ខេត្តតាកែវ )<br>ផ្លូវជាតិលេខ ២ | ទិន បៀន ( ខេត្តអាន យ៉ាង )<br>ផ្លូវជាតិលេខ ២ |
| ៨. | លក ( ខេត្តកំពត )<br>ផ្លូវជាតិលេខ ១៧ | សាសៀ ( ខេត្តគៀន យ៉ាង )<br>ផ្លូវជាតិលេខ ១៧ |

ប្រសិនបើភាគីណាមួយមានសំណូមពរ និងក្រោយពីការផ្លាស់ប្តូរមតិឯកភាពគ្នា ភាគីទាំងពីរនឹងបន្តបើកមាត់ច្រកមួយចំនួនទៀត ដើម្បីបង្ករលក្ខណៈងាយស្រួល អោយទំនិញឆ្លងកាត់ ។

## ប្រការ ៣

រូបភាពឆ្លងកាត់រូមមាន :

១. ឆ្លងកាត់ដោយស្តុកឃ្លាំងដោយប្តូរមធ្យោបាយដឹកជញ្ជូន ប្តូរសំបកវេចខ្ចប់ វេចខ្ចប់ឡើងវិញ នៅប្រទេសអោយ ឆ្លងកាត់ ។

២. ឆ្លងកាត់ដោយ មិនស្តុកឃ្លាំង មិនផ្ទេរមធ្យោបាយដឹកជញ្ជូន នៅប្រទេសអោយឆ្លងកាត់ ហៅកាត់ថា ឆ្លងកាត់ត្រង់ ។

VHORA

## ប្រការ ៤

ការដឹកជញ្ជូនទំនិញឆ្លងកាត់ត្រូវគោរពតាមការកំណត់ ដូចតទៅ :

១- ត្រូវគោរពតាមបទបញ្ញត្តិរបស់គយ នៃប្រទេសអោយឆ្លងកាត់ ។

២- បរិមាណនិង យថាប្រភេទ ទំនិញដឹកជញ្ជូនចូលតាមមាត់ច្រកណាមួយ ត្រូវដូចនិងស្មើនឹងបរិមាណ យថាប្រភេទ ទំនិញចេញតាមមាត់ច្រកនៃប្រទេសអោយឆ្លងកាត់ ។ទំនិញត្រូវរក្សាលក្ខណៈដើមទាំងសំបកវេចខ្ចប់ទាំងផ្លុំបេរបស់គយ ។ក្នុងករណីទំនិញមានការបាត់បង់ខូចខាតឬ បាក់បែកត្រូវតែមានលិខិតបញ្ជាក់របស់គយនៅកន្លែងកើតហេតុ។ ក្នុងករណីមានទំនិញបាត់បង់ នឹងខូចខាត ដែលកើតឡើងដោយករណីប្រធានសក្តិដូចជាគ្រោះថ្នាក់ធម្មជាតិគ្រោះថ្នាក់អគ្គិភ័យ ។ ល ។ ត្រូវមានការបញ្ជាក់ដោយលាយលក្ខណ៍អក្សររបស់អាជ្ញាធរដែនដី ឬ គយ កន្លែងកើតហេតុ ។

៣- ទំនិញឆ្លងកាត់គ្រប់ត្រូវដឹកជញ្ជូនតាមតម្រាយផ្លូវ ឆ្ពោះទៅកាន់ច្រក តាមមធ្យោបាយដឹកជញ្ជូន និងទម្ងន់ផ្ទុកត្រឹមត្រូវតាមពេលវេលា ដែលបានកំណត់ក្នុងលិខិតអនុញ្ញាតអោយឆ្លងកាត់( បើសិនមាន ) និង ស្ថិតក្រោមការត្រួតពិនិត្យ របស់គយនៃប្រទេសអោយឆ្លងកាត់ ។

៤- ក្នុងករណីទំនិញឆ្លងកាត់ត្រូវស្តុកឃ្លាំងនៅក្នុងប្រទេសអោយឆ្លងកាត់ ទំនិញទាំងនោះត្រូវមានការអនុញ្ញាតិ អោយឆ្លងកាត់ ដោយកំណត់ពេលវេលា និង ទីកន្លែងព្រមទាំងស្ថិតក្រោមការត្រួតពិនិត្យ និង តាមដាន របស់គយនៃប្រទេសអោយឆ្លងកាត់ ។

## ប្រការ ៥

ភាគីចុះហត្ថលេខានិមួយៗ អនុញ្ញាតអោយទំនិញរបស់ភាគីម្ខាងបានឆ្លងកាត់លើទឹកដីរបស់ខ្លួន តាមបទបញ្ញត្តិដូចតទៅ :

១- ចំពោះបញ្ជីទំនិញហាមនាំចូល និង ហាមនាំចេញ :

១-១ មិនត្រូវបានអនុញ្ញាតអោយឆ្លងកាត់លើទឹកដីនៃភាគីចុះហត្ថលេខាណាមួយ នូវទំនិញដែលត្រូវបាន

VHORA

ហាមឃាត់ធ្វើអាជីវកម្មដោយច្បាប់ និងទម្លាប់អន្តរជាតិដូចជាគ្រឿងញៀន ជាតិគីមីពុល ជាតិវិទ្យុសកម្ម វប្បធម៌ អាសអាភាស ប៉ះពាល់ដល់ឯករាជ្យភាពអធិបតេយ្យភាព និង សន្តិសុខ របស់ភាគីចុះហត្ថលេខាណាមួយ និង សត្វព្រៃគ្រប់ប្រភេទដែលកម្រកបាន និង មានតំលៃនិងជិតផុតពូជ ។

១-២ ក្នុងករណីទំនិញឆ្លងកាត់ ជាគ្រឿងសញ្ញាវុធគ្រាប់រំសេវ ជាតិផ្ទុះសំភារៈបច្ចេកទេស និង បរិក្ខាយោធា សំរាប់វិស័យការពារជាតិ និង សន្តិសុខជាតិនោះត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃប្រទេសអោយឆ្លងកាត់ តាមសំណូមពររបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃប្រទេសសុំឆ្លង កាត់ ។

១-៣ ចំពោះការឆ្លងកាត់ទំនិញដែល ប្រទេសអនុញ្ញាតអោយឆ្លងកាត់ ហាមនាំចេញឬហាមនាំចូល ប៉ុន្តែភាគីស្នើសុំឆ្លងកាត់មិនហាមឃាត់ ការឆ្លងកាត់ទំនិញប្រភេទនេះ ត្រូវបានអនុវត្តន៍ដូចតទៅ :

ក) ការឆ្លងកាត់ទំនិញតាមផ្លូវទឹកតាមដងទន្លេ សុងទៀនគីវឡុង-ទន្លេមេគង្គតាមច្រកព្រំដែនផ្លូវទឹកដូចដែលបានចែងក្នុងប្រការ២នៃកិច្ចព្រមព្រៀងនេះម្ចាស់ទំនិញ ឬ នាវាដែលបានទទួលសិទ្ធិពីម្ចាស់ទំនិញ(ហៅកាត់អ្នកដឹកជញ្ជូន)ត្រូវធ្វើបែបបទគយ អោយទំនិញឆ្លងកាត់តាមផ្លូវទឹក នៅច្រកព្រំដែនចូល ដោយមិនចាំបាច់សុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្មរបស់ប្រទេសអោយឆ្លងកាត់ទេ ។

ខ) ការឆ្លងកាត់តាមផ្លូវគោក(គិតទាំងផ្លូវដែកដឹកជញ្ជូនអន្តរជាតិបើសិនមានពេលក្រោយ)តាមច្រកព្រំដែនផ្លូវគោក ដូចបានចែងក្នុងប្រការ ២ នៃកិច្ចព្រមព្រៀងនេះ ម្ចាស់ទំនិញ ឬ អ្នកដឹកជញ្ជូនត្រូវសុំការអនុញ្ញាតអោយទំនិញឆ្លងកាត់ពីក្រសួងពាណិជ្ជកម្ម របស់ប្រទេសឱយឆ្លងកាត់តាមសំណូមពរជាលាយលក្ខណ៍អក្សរ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃប្រទេសសុំ ឆ្លងកាត់ ។
បញ្ជីរាយមុខទំនិញហាមនាំចេញ និង ហាមនាំចូល របស់ភាគីនិមួយៗ បានលើកឡើងក្នុងឧបសម្ព័ន្ធ 0១ (របស់វៀតណាម ) និង ឧបសម្ព័ន្ធ 0២ (របស់កម្ពុជា) ជូនភ្ជាប់ ។ បញ្ជីរាយមុខទំនិញនេះអាចផ្លាស់ប្តូរបានរៀងរាល់ឆ្នាំ។ នៅពេលមានការផ្លាស់ប្តូរបញ្ជីទំនិញនេះ ភាគីនីមួយៗត្រូវជូនដំណឹងគ្នាអោយទាន់ពេលវេលាផង ។និងបញ្ជីមុខទំនិញថ្មី ត្រូវបានយកមកដាក់ជួសបញ្ជីមុខទំនិញឆ្នាំមុន និង ក្លាយជាឧបសម្ព័ន្ធថ្មី របស់កិច្ចព្រមព្រៀងក្នុងឆ្នាំនេះ ។

THORA

២- ចំពោះទំនិញដែលមិនចែងក្នុងចំណុច ១.១ . ១.២ ១.៣ និង ១ នៅក្នុងប្រការនេះ នៅពេលឆ្លងកាត់ទឹកដីរបស់ភាគីចុះហត្ថលេខាម្ខាងទៀត តាមផ្លូវគោក ឬផ្លូវទឹក ម្ចាស់ទំនិញ ឬ អ្នកដឹកជញ្ជូនគ្រាន់តែធ្វើបែបបទគយ អោយទំនិញឆ្លងកាត់នៅច្រកព្រំដែន ដោយមិនចាំបាច់សុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្មនៃប្រទេសអោយឆ្លងកាត់ឡើយ ។

## ប្រការ ៦

ការឆ្លងកាត់ឈើ និងផលិតផលឈើឆ្លងប្រទេសនៃភាគីចុះហត្ថលេខានិមួយៗត្រូវអនុវត្តន៏ដូចតទៅ :

១- មិនអនុញ្ញាតអោយដឹកជញ្ជូនឆ្លងកាត់ឈើមូល ឆ្លងកាត់ប្រទេសនៃភាគីចុះហត្ថលេខាណាមួយឡើយ (ឈើមូលមានន័យថា ជាឈើមូលទាំងដើម បកសំបក ឬ មិនទាន់បកសំបក សាច់ឈើស្រាយពីក្រៅខាងក្នុងខ្ទឹមឬមានរាងជ្រុង) ។

២- ការឆ្លងកាត់ឈើអារ ត្រូវមានលិខិតអនុញ្ញាត្តរបស់ក្រសួងពាណិជ្ជកម្ម នៃប្រទេសអោយឆ្លងកាត់តាមសំណើរជាលាយលក្ខ័ណអក្សររបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រទេសសុំឆ្លងកាត់ ។

៣- ការឆ្លងកាត់ផលិតផលឈើគ្រប់ប្រភេទ ម្ចាស់ទំនិញត្រូវធ្វើបែបបទគយនៅមាត់ច្រកព្រំដែន ហើយពុំចាំបាច់សុំលិខិតអនុញ្ញាតឆ្លងកាត់នៅ ក្រសួងពាណិជ្ជកម្ម នៃប្រទេសឱ្យឆ្លងកាត់ទេ ។

៤- ប្រទេសសុំឆ្លងកាត់ ត្រូវគោរពរាល់បទបញ្ញត្តិជាចាំបាច់ ដើម្បីធានាថា ទំនិញដែលមានចែងក្នុងចំណុចទី៣ ខាងលើ គឺជាទំនិញដែលបានអនុញ្ញាតិនាំចេញស្របច្បាប់ ពីប្រទេសសុំឆ្លងកាត់ ។

## ប្រការ ៧

ទំនិញឆ្លងកាត់មិនអនុញ្ញាតអោយលក់ដូរក្នុងទឹកដីនៃប្រទេសអោយឆ្លងកាត់ឡើយ ។ ក្នុងករណីពិសេសដែលក្រសួងពាណិជ្ជកម្មនៃប្រទសអោយឆ្លងកាត់អនុញ្ញាតអោយលក់ដូរទំនិញឆ្លងកាត់នោះ ក្នុងទឹកដីរបស់ប្រទេសឱ្យឆ្លងកាត់ ម្ចាស់ទំនិញរបស់ប្រទេសសុំឆ្លងកាត់ត្រូវបង់ពន្ធ និងបន្ទុកផ្សេងៗតាមច្បាប់បទបញ្ញត្តិរបស់ប្រទេសអោយឆ្លងកាត់ ។

THORA

## ប្រការ ៨

១- ក្នុងករណីទំនិញឆ្លងកាត់ដឹកជញ្ជូនតាមផ្លូវគោក ម្ចាស់ទំនិញ ឬ អ្នកដឹកជញ្ជូន អាចប្រើប្រាស់មធ្យោបាយដឹកជញ្ជូនផ្លូវគោករបស់ខ្លួន ឬ ជួលមធ្យោបាយដឹកជញ្ជូន ផ្លូវគោករបស់ប្រទេស អោយឆ្លងកាត់ ។

២- ក្នុងករណីទំនិញឆ្លងកាត់ដឹកជញ្ជូនតាមផ្លូវទឹកម្ចាស់ទំនិញ ឬអ្នកដឹកជញ្ជូនអាចប្រើប្រាស់មធ្យោបាយផ្លូវទឹករបស់ខ្លួន ឬ ជួលមធ្យោបាយដឹកជញ្ជូនផ្លូវទឹករបស់ប្រទេសអោយឆ្លងកាត់ឬជួលមធ្យោបាយដឹកជញ្ជូនរបស់ប្រទេសទី៣ ។ ប៉ុន្តែត្រូវគោរពតាមបទបញ្ញត្តិ ស្តីពីមធ្យោបាយដឹកជញ្ជូនរបស់ប្រទេសអោយ ឆ្លងកាត់ ។

៣- ទំរង់បែបបទស្តីពីមធ្យោបាយដឹកជញ្ជូនសំរាប់ផ្ទេរទំនិញឆ្លងកាត់ ការផ្ទេរនាវា ត្រូវគោរពតាមបទបញ្ញតិជាធរមាន របស់ប្រទេសអោយឆ្លងកាត់និងអនុវត្តន៍ស្របតាម កិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវគោកដែលបានចុះហត្ថលេខា ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៩៨ និងកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវទឹកដែលបានចុះហត្ថលេខា ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៨ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

## ប្រការ ៩

រាល់កំរៃបែបបទ និង ចំណាយផ្សេងៗកើតឡើងពីសកម្មភាព ដឹកទំនិញឆ្លងកាត់តាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះត្រូវទូទាត់ជារូបិយវត្ថុរបស់ប្រទេស អោយឆ្លងកាត់ឬរូបិយប័ណ្ណ ប្តូរផ្ទេរដោយសេរីស្របទៅតាមបទបញ្ញត្តិ នៃការគ្រប់គ្រងរូបិយប័ណ្ណ របស់ប្រទេសនិមួយ ៗ ។

## ប្រការ ១០

១- ផ្អែកតាមសភាពការណ៍ជាក់ស្តែង ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋសង្គមនិយមវៀតណាមត្រូវពិភាក្សាគ្នា ហើយចុះហត្ថលេខាលើលិខិតផ្សេងៗ ដើម្បីអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

២- ក្រោយពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះហើយ ភាគីទាំងពីរ ត្រូវផ្សព្វផ្សាយ ឯកសារដែលទាក់ទងដល់ការណែនាំអនុវត្តកិច្ចព្រមព្រៀងនេះ ហើយជូនដំណឹងដល់ភាគីម្ខាងទៀត ដើម្បីឯកភាពអនុវត្ត ។

## ប្រការ ១១

រាល់ទំនាស់ដែលកើតឡើងដោយថាហេតុ ពីការបកស្រាយ ក្នុងដំណើរការអនុវត្ត កិច្ចព្រមព្រៀងនេះត្រូវបានពិគ្រោះនិងពិភាក្សាតាមផ្លូវការទូតដោយតំណាងមានសមត្ថកិច្ច របស់ភាគីទាំង ២ ។

## ប្រការ ១២

ក្នុងរយៈពេលសុពលភាពនៃកិច្ចព្រមព្រៀង បើភាគីណាមួយនៃភាគីចុះកិច្ចព្រមព្រៀងទាំងពីរ មានបំណងបំពេញបន្ថែមឬកែសម្រួលប្រការនានាដែលបានចុះហត្ថលេខា ត្រូវធ្វើសំណើរជាលាយលក្ខណ៍អក្សរ ។

ក្នុងរយៈពេល០៣ខែគិតចាប់ពីថ្ងៃទទួលសំណើ ភាគីទទួលនោះត្រូវឆ្លើយតបតាមផ្លូវការជាលាយលក្ខណ៍អក្សរវិញ ។ ការកែប្រែឬបំពេញបន្ថែមដែលភាគីទាំងពីរបានឯកភាពគ្នាត្រូវបានបញ្ចូល ជាចំណែកមួយមិនអាចផ្តាច់បានរបស់ កិច្ច ព្រមព្រៀងនេះ នឹងមានប្រសិទ្ធិភាពដូចកិច្ចព្រមព្រៀងនេះដែរ ។

## ប្រការ ១៣

១- កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅនិងមានតំលៃសំរាប់រយៈពេលពីរឆ្នាំ និង ជំនួស កិច្ចព្រមព្រៀងស្តីពីទំនិញឆ្លងកាត់រវាងប្រទេសទាំងពីរដែលបានចុះហត្ថលេខា ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ១៩៩៤ និង ពិធីសារស្តីពីការកែប្រែនិងបំពេញបន្ថែមប្រការមួយចំនួន របស់កិច្ចព្រមព្រៀងស្តីពីទំនិញឆ្លងកាត់ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៥ និង លិខិតផ្លូវការរវាងរដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម របស់ប្រទេសទាំងពីរ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបើកមាត់ច្រកព្រំដែន ។

ប្រសិនបើក្នុងរយៈពេល ០៣ខែមុនពេលកិច្ចព្រមព្រៀងអស់សុពលភាព ពុំមានភាគីណាមួយនៃភាគីទាំងពីរមានសំណើជាលាយលក្ខណ៍អក្សរដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះទេ កិច្ចព្រមព្រៀងនេះនិង ត្រូវបន្តដោយ ស្វ័យប្រវត្តិសំរាប់រយៈពេល មួយ ឆ្នាំទៀត និង បន្តជាថ្មីទៀតតាមវិធីដដែល ។

២- នៅពេលកិច្ចព្រមព្រៀងនេះផុតសុពលភាពប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ នៅតែត្រូវបានអនុវត្តសំរាប់ការព្រមព្រៀងនានាដែលបានចុះហត្ថលេខា មុនពេលបញ្ចប់សុពលភាពនៃ កិច្ចព្រមព្រៀងនេះ រហូតដល់ពេលអនុវត្តចប់សព្វគ្រប់ជាស្ថាពរ ។

ដើម្បីជាសក្ខីភាពអ្នកចុះហត្ថលេខាខាងក្រោម ដែលបានទទួលសិទ្ធិប្រទានពីរដ្ឋាភិបាលរៀងៗខ្លួនយ៉ាងពិតប្រាកដ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០០ ជាពីរច្បាប់ដើម ជាភាសាខ្មែរ វៀតណាមនិង ភាសាអង់គ្លេស ដែលមានតំលៃអនុវត្តដូចគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា ច្បាប់ជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ធ្វើជាច្បាប់គោល ។

| | |
|---|---|
| **តំណាងរដ្ឋាភិបាលនៃ** | **តំណាងរដ្ឋាភិបាលនៃ** |
| **ព្រះរាជាណាចក្រកម្ពុជា** | **សាធារណរដ្ឋសង្គមនិយមវៀតណាម** |
| **ចម ប្រសិទ្ធ** | **វូ ឃាន់** |
| **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** | **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** |

## ឧបសម្ព័ន្ធ ០១

## បញ្ជីរាយមុខទំនិញហាមនាំចេញ និងនាំចូល របស់វៀតណាម ឆ្នាំ ២០០០

### I. ទំនិញហាមនាំចេញ

១- គ្រឿងសព្វាវុធ គ្រាប់រំសេវ ជាតិរំសេវ ជាតិផ្ទុះ សំភារៈបរិក្ខារបច្ចេកទេសយោធា

២- វត្ថុបុរាណ

៣- គ្រឿងញៀនគ្រប់ប្រភេទ

៤- ជាតិគីមីពុល

៥- ឈើមូល ឈើអារ កាប់ចេញពីព្រៃធម្មជាតិ ផលិតផល ផលិតផលពាក់កណ្តាលសំរេច ធ្វើពីឈើព្រៃធម្មជាតិ របស់វៀតណាម

៦- សត្វព្រៃ រុក្ខជាតិ ធម្មជាតិ ដែលកម្រកេបាន និងមានតំលៃ ។

### II. ទំនិញហាមនាំចូល

១- គ្រឿងសព្វាវុធ គ្រាប់រំសេវ ជាតិរំសេវ ជាតិផ្ទុះ សំភារៈបរិក្ខារបច្ចេកទេសយោធា

២- គ្រឿងញៀនគ្រប់ប្រភេទ

៣- ជាតិគីមីពុល

៤- វប្បធម៌ពាលាអាក្រាំសៃ អាសអាភាស

៥- ផាវគ្រប់ប្រភេទ ប្រដាប់សំរាប់ក្មេងលេង ដែលជះឥទ្ធិពលអាក្រក់ដល់ការអប់រំ សម្បជញ្ញៈ និងសន្តិសុខសណ្តាប់ធ្នាប់សង្គម

៦- បារី ( លើកលែងបុគ្គលដែលយកតាមខ្លួនពេលធ្វើដំណើរ ដោយកំណត់ចំនួន )

៧- ទំនិញប្រើប្រាស់ចាស់ៗ ( លើកលែងឥវ៉ាន់រួមដំណើរព្រមទាំងឥវ៉ាន់ ( ទំនិញ ) ជាសេចក្តីត្រូវការរបស់បុគ្គលផ្នែកការបរទេស នៃបណ្តាប្រទេស និងបណ្តាអង្គការអន្តរជាតិ និង ឥវ៉ាន់អ្នកដំណើរតាមការកំណត់ ) ។

៨- រថយន្តចង្កូតស្តាំ ព្រមទាំងប្រភេទ ដោះរាយ និងប្រភេទដូរចង្កូតមុនពេលនាំចូលវៀតណាម លើកលែងមធ្យោបាយពិសេស ចង្កូតស្តាំ ក្នុងសកម្មភាពក្រុមខណ្ឌតូចរួមមាន : រថយន្តស្ទូច ម៉ាស៊ីនជីកប្រឡាយ លូ រថយន្តបោសសំអាតផ្លូវ រថយន្តដឹកសំរាម រថយន្តអ៊ុតថ្នល់ រថយន្តដឹកអ្នកដំណើរក្នុងអាកាសយានដ្ឋាន រថយន្តលើកទំនិញក្នុងឃ្លាំង និងក្នុងកំពង់ផែ ។

៩- ទំនិញដែលប្រើប្រាស់រួចហើយ រួមមាន : គ្រឿងបន្លាស់ គ្រឿងម៉ាស៊ីន តួ កង់រថយន្តគ្រប់ប្រភេទ ទោចក្រយានយន្ត ត្រីចក្រយានយន្ត រ៉ឺម៉ក់សណ្តោងរថយន្តគ្រប់ប្រភេទ រថយន្តពី១៦កៅអីចុះ រថយន្តដឹកអ្នកដំណើរគ្រប់ប្រភេទ និងរថយន្តចំណុះក្រោម ៥តោន ហើយផលិមុនឆ្នាំ ១៩៩៥ ។

១០- ផលិតផលសំភារៈមានជាតិ Amianthus ស្ថិតក្នុងក្រុម Amphibole

# ឧបសម្ព័ន្ធ ០២

## បញ្ជីរាយមុខទំនិញហាមនាំចេញ និងនាំចូល របស់កម្ពុជាឆ្នាំ២០០០

### I. ទំនិញហាមនាំចេញ

១- គ្រឿងសញ្ញាវុធ សំភារៈជាតិផ្ទុះ សំភារៈបរិក្ខាយោធា

២- គ្រឿងញៀន គ្រប់ប្រភេទ

៣- ត្បូងមានតំលៃ : មាសនៅ ត្បូងមិនទាន់កែឆ្នៃ ឬ វត្ថុធាតុដើមត្បូងមិនទាន់កែឆ្នៃ ដែលជាកម្មវត្ថុ ដែលបានកំណត់ដោយប្រកាសរបស់ធនាគារកណ្តាល បើសិនជាមានតំលៃស្មើឬលើសពីមួយម៉ឺនដុល្លាអាមេរិក។

៤- ផលិតផលព្រៃឈើ :

-ឈើមូល ទោះបកសំបក ឬទាំងសំបក

-ឈើអារសុទ្ធសាធ

-ឈើជ្រុងដែលមានកំរាស់ លើសពី ២៥ស.ម ទោះបីបានឈូសក៏ដោយ

-អុសគ្រប់ប្រភេទ ទោះបីចង់ជាបាច់ក៏ដោយ

-ធ្យូងឈើ

### II. ទំនិញហាមនាំចូល

១- គ្រឿងសញ្ញាវុធ សំភារៈជាតិផ្ទុះ សំភារៈបរិក្ខាយោធា

២- គ្រឿងញៀន គ្រប់ប្រភេទ

៣- ត្បូងមានតំលៃ : មាសនៅ ត្បូងមិនទាន់កែឆ្នៃ ឬវត្ថុធាតុដើមត្បូងមិនទាន់កែឆ្នៃ ដែលជាកម្មវត្ថុ ដែលបានកំណត់ដោយប្រកាសរបស់ធនាគារកណ្តាល បើសិនជាមានតំលៃស្មើឬលើសពីមួយម៉ឺនដុល្លាអាមេរិក។

THOAI ៤- ស្បែកជើងប្រើហើយ